## សំណួរទាំងឡាយដែលគេតែងសួរជាញឹកញាប់

**ស. តើខ្ញុំគួរប្រើសាប៊ូ និងទឹក ឬថ្នាំលាងសំអាតដែលមានជាតិស្រា ដើម្បីលាងសំអាតដៃរបស់ខ្ញុំ?**

ឆ. លោកអ្នកអាចប្រើសាប៊ូ ឬទឹក ឬថ្នាំដែលមានជាតិស្រា ដើម្បីលាងសំអាតដៃរបស់លោកអ្នក។

**ស. តើខ្ញុំនឹងឃើញបុគ្គលិកមើលថែសុខភាព ប្រើថ្នាំលាងសំអាតដែលមានជាតិស្រាឬទេ?**

ឆ. មែនហើយ។ ក្នុងអំឡុងពេលលោកអ្នកទៅមន្ទីរពេទ្យ លោកអ្នកនឹងឃើញបុគ្គលិកមើលថែសុខភាពលាងសំអាតដៃរបស់គេយ៉ាងញឹកញាប់ជាមួយថ្នាំលាងសំអាតដៃដោយប្រើថ្នាំលាងសំអាតដែលមានជាតិស្រា មុន និងក្រោយគេបានពិនិត្យមើលលោកអ្នក ញាតិសន្តាន ឬមិត្តភក្តិ។ បុគ្គលិកមើលថែសុខភាពបានទទួលការហ្វឹកហ្វឺនក្នុងការប្រើវិធានការអនាម័យដៃដើម្បីបង្ការមេរោគ។

**ស. តើថ្នាំលាងសំអាតដែលមានជាតិស្រា នឹងសម្លាប់មេរោគដែលស្ថិតនៅពីលើដៃរបស់ខ្ញុំឬ?**

ឆ. ថ្នាំលាងសំអាតដែលមានជាតិស្រានឹងសម្លាប់៩៩.៩ ភាគរយនៃមេរោគដែលស្ថិតនៅពីលើដៃរបស់លោកអ្នក។

សូមចងចាំ

លោកអ្នកមានសិទ្ធិដើម្បីសួរថា

**តើលោកអ្នកបានលាងសំអាតដៃរបស់លោកអ្នកហើយឬនៅ?**

ដើម្បីទទួលយកព័ត៌មានបន្ថែម សូមទាក់ទងភ្នាក់ងារគំរោង ឬនាយកគ្រប់គ្រងមេរោគរបស់ **Eastern Health Hand Hygiene**។ សូមសួរនាយកក្រុមគិលានុបដ្ឋាកដើម្បីទទួលយកព័ត៌មានទាក់ទងលំអិត។

**កិច្ចបំរើបកប្រែភាសាសំរាប់អស់អ្នកដែលមានបញ្ហាភាសាអង់គ្លេស។**

ប្រសិនបើលោកអ្នកចង់សួរសំណួរណាមួយអំពីព័ត៌មានដែលមានចុះនៅក្នុងកូនសៀវភៅនេះ សូមប្រាប់បុគ្គលិកថាលោកអ្នកត្រូវការអ្នកបកប្រែភាសា នៅពេលនោះគេនឹងរៀបចំឲ្យមានម្នាក់ដើម្បីជួយលោកអ្នក។ កិច្ចបំរើនេះឥតគិតថ្លៃពីលោកអ្នកឡើយ។

Eastern Health បានទទួលស្គាល់ជាផ្លូវការដោយក្រុមប្រឹក្សាអូស្ត្រាលីឯករាជ្យផ្នែកស្តង់ដារសុខភាពមើលថែ ក្នុងការទទួលស្គាល់នៃការសំរេចបាននូវស្តង់ដារដែលមានការទទួលស្គាល់ និងការប្តូរផ្តាច់ដើម្បីបន្តការកែលំអក្នុងការផ្តល់នូវកិច្ចបំរើមើលថែសុខភាព។

Clive Ward Centre, 16 Arnold Street,
5 Arnold Street
Box Hill Victoria 3128, Australia
PO Box 94, Box Hill 3128
ទូរស័ព្ទ: (03) 9895 3259 ទូរសារ: (03) 9895 3176
អ៊ីម៉េល: info@easternhealth.org.au
វ៉ិបសាយ: www.easternhealth.org.au

© Eastern Health 2008

អនុញ្ញាតដោយ Eastern Health EH0908 IC007

*Translated into Cambodian (Khmer)*

# អនាម័យលាងសំអាតដៃ

## ព័ត៌មានសំរាប់អ្នកជម្ងឺ ញាតិសន្តាន និងអ្នកមើលថែ

Infection Prevention
It's In Your Hands

## *ហេតុអ្វីបានជាយើងត្រូវលាងសំអាតដៃរបស់យើង?*

ការលាងសំអាតដៃជាមួយសាប៊ូ និងទឹក ឬការលាងសំអាតជាមួយថ្នាំលាងសំអាតដែលមានជាតិស្រា យកចេញនូវមេរោគពីដៃរបស់យើងដែលអាចបណ្តាលឲ្យកើតទៅជាជម្ងឺ។

ការយកចេញនូវមេរោគទាំងនេះ កាត់បន្ថយឱកាសដែលយើងនឹងឈឺ ឬចម្លងជម្ងឺទៅអ្នកផ្សេងទៀត។

យើងសូមលើកទឹកចិត្តលោកអ្នកឲ្យចូលរួមជាមួយបុគ្គលិកមើលថែសុខភាពក្នុងការផ្សព្វផ្សាយអំពីការអនុវត្តន៍ដ៏សំខាន់នេះ ដោយលាងសំអាតដៃរបស់លោកអ្នក នៅពេលចូលមកដល់ ឬចាកចេញពីមន្ទីរពេទ្យរបស់យើង។

ឱកាសទាំងឡាយទៀតសំរាប់អនាម័យលាងសំអាតដៃមានរួមទាំង:

- បន្ទាប់ពីទៅបង្គន់
- មុនពេលលោកអ្នកបរិភោគ ឬពិសារវត្ថុរាវ
- បន្ទាប់ពីប្រើក្រដាសជូតមាត់ដើម្បីជូតច្រមុះរបស់លោកអ្នក។




### *ប្រសិនបើលោកអ្នកមិនអាចប្រើថ្នាំលាងសំអាតដែលមានជាតិស្រា ដោយព្រោះមូលហេតុសាសនា ឬវប្បធម៌ សូមប្រើសាប៊ូ និងទឹកដើម្បីលាងសំអាតដៃរបស់លោកអ្នក។*

### របៀបប្រើថ្នាំលាងសំអាតដែលមានជាតិស្រា

សង្កត់ដងបញ្ចេញទឹកលាងសំអាតនៅពីលើដប ដើម្បីបញ្ចេញចំនួនតិចនៃថ្នាំលាងសំអាតដែលមានជាតិស្រា។

ត្រដុសថ្នាំលាងសំអាតពេញសព្វទៅលើដៃទាំងពីរ ដើម្បីឲ្យបានច្បាស់ថាលោកអ្នកបានត្រដុសពេញសព្វផ្ទៃដៃមានរួមទាំងកដៃផងដែរ។ សូមត្រដុសរហូតទាល់តែថ្នាំលាងសំអាតវាស្ងួតអស់។

១. បាញ់ច្រូចតែ១ដងទៅលើបាតដៃរបស់លោកអ្នក



២. ត្រដុសដៃទាំងពីរជាមួយគ្នា



៣. ត្រដុសពីលើផ្ទៃដៃទាំងពីររហូតទាល់តែវាស្ងួត

